Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ដឹងពីហានិភ័យនៃទឹកជំនន់ របស់អ្នក

## ស្វែងយល់អំពីហានិភ័យនៃទឹកជំនន់របស់អ្នក

- ទាក់ទងសាលាសង្កាត់របស់អ្នកសម្រាប់ព័ត៌មាននៅតាមមូលដ្ឋានអំពីហានិភ័យទឹកជំនន់របស់អ្នក។
- ទាក់ទងអង្គភាព NSW SES ក្នុងតំបន់របស់អ្នកសម្រាប់ព័ត៌មានអំពីទឹកជំនន់នៅតាមមូលដ្ឋាន។ ក៏អាចមានព័ត៌មានអំពីទឹកជំនន់នៅតាមតំបន់ នៅលើ **គេហទំព័រ NSW SES**ផងដែរ។
- និយាយជាមួយអ្នកជិតខាង និងអ្នកស្នាក់នៅក្នុងតំបន់ដែលបានរស់នៅ ធ្វើការ ឬមកលេងនៅតំបន់នោះអស់រយៈពេលជាយូរមកហើយ ដើម្បីទទួលបានព័ត៌មានអំពីទឹកជំនន់ដែលមានក្នុងប្រវត្តិសាស្ត្រ។
- ស្រាវជ្រាវមើលពីកម្ពស់ផ្ទះ អាជីវកម្ម ឬទ្រព្យសម្បត្តិរបស់អ្នកដែលអាចរងផលប៉ះពាល់ដោយទឹកជំនន់។ ព័ត៌មាននេះគួរតែអាចរកបានពីសាលាសង្កាត់របស់អ្នក។
- ត្រូវប្រាកដថាអ្នកមានគោលការណ៍ធានារ៉ាប់រងត្រឹមត្រូវដើម្បីធានាលើការខូចខាតដោយទឹកជំនន់សម្រាប់ផ្ទះ និងទ្រព្យសម្បត្តិរបស់អ្នក។



## ត្រូវដឹងអំពីផលប៉ះពាល់នៃទឹកជំនន់

មានផលប៉ះពាល់ជាច្រើននៃទឹកជំនន់ ឧទាហរណ៍៖

- ការខូចខាតដល់ផ្ទះ អាជីវកម្ម ឬទ្រព្យសម្បត្តិរបស់អ្នក
- ការដាច់ថាមពល និងការផ្គត់ផ្គង់ទឹក
- ការនៅដាច់ពីគេឯង។ សូម្បីតែផ្ទះសម្បែងរបស់អ្នកមិនរងទឹកជំនន់ក៏ដោយ អ្នកអាចត្រូវបានឡោមព័ទ្ធដោយទឹកជំនន់ជោគជាំ
- ការបាត់បង់ការតភ្ជាប់ទំនាក់ទំនង
- ការខូចខាតដល់ប្រព័ន្ធលូបង្ហូរទឹក
- ទឹកជំនន់លើផ្លូវ ស្ពាន និងកន្លែងនានាដែលអ្នកទៅលេង

ក្នុងស្ថានភាពគំរាមកំហែងដល់ជីវិត **ហៅទូរសព្ទទៅលេខសូន្យបីង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES

Khmer | ភាសាខ្មែរ

NSW STATE EMERGENCY SERVICE

# ដឹងពីហានិភ័យនៃទឹកជំនន់ របស់អ្នក

## ដឹងអំពី អ្វីខ្លះដែលត្រូវធ្វើ និងកន្លែងដែលត្រូវទៅ



មានផែនការសង្គ្រោះបន្ទាន់សម្រាប់ផ្ទះ អាជីវកម្ម និងទ្រព្យសម្បត្តិរបស់អ្នក។ រៀបចំផែនការសម្រាប់មនុស្ស និងសត្វទាំងអស់ដែលស្ថិតនៅក្នុងការថែទាំរបស់អ្នក។



ចែករំលែកផែនការសង្គ្រោះបន្ទាន់របស់អ្នកជាមួយគ្រួសារ អ្នកជិតខាង និងសហការី ហើយពិនិត្យវាឡើងវិញជាប្រចាំ។



រៀបចំផែនការសម្រាប់ផ្លូវធ្វើដំណើរដែលមានសុវត្ថិភាពសម្រាប់សេណារីយ៉ូនៃការបិទផ្លូវផ្សេងៗគ្នា។



រៀបចំផែនការចាកចេញឱ្យបានមុន។



រៀបចំកន្លែងមានសុវត្ថិភាពដែលនឹងត្រូវទៅដែលស្ថិតនៅក្រៅតំបន់មានហានិភ័យទឹកជំនន់ ដូចជានៅផ្ទះមិត្តភក្តិ ឬសាច់ញាតិ។ ប្រសិនបើវាមិនមែនជាជម្រើសទេ នោះចូររៀបចំផែនការទៅកាន់មជ្ឈមណ្ឌលជម្លៀស។

## រៀបចំ កញ្ចប់សង្គ្រោះបន្ទាន់

- វិទ្យុចល័តដែលមានថ្មបម្រុងទុក
- ពិលដែលមានថ្មបម្រុង
- កញ្ចប់សង្គ្រោះបឋម (ជាមួយនឹងការផ្គត់ផ្គង់ចាំបាច់សម្រាប់គ្រួសាររបស់អ្នក)
- ទៀន និងឈើគូសមិនជ្រាបទឹក




## ត្រូវដឹងព័ត៌មាន

ទាញយកកម្មវិធី **គ្រោះថ្នាក់នៅជិតខ្ញុំ (Hazards Near Me app)** ចូលទៅក្នុងឧបករណ៍ចល័តរបស់អ្នក និងបង្កើត **តំបន់ឃ្លាំមើល** សម្រាប់តំបន់នានាដែលអ្នករស់នៅ ធ្វើការ និងទៅលេង។

ក្នុងស្ថានភាពគំរាមកំហែងដល់ជីវិត **ហៅទូរសព្ទទៅលេខសូន្យបីដង (000)**

សម្រាប់ជំនួយសង្គ្រោះបន្ទាន់សម្រាប់ទឹកជំនន់ ព្យុះភ្លៀង និងរលកយក្សស៊ូណាមិ សូមហៅទូរសព្ទទៅ **NSW SES** តាមលេខ **132 500**។

**www.ses.nsw.gov.au/languages**

@NSWSES NSWSES NSWSES